ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ:.......០០២.............សសរ.សក

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមអ្នកនាំពាក្យ នៃក្រសួងសាធារណការ និងដឹកជញ្ជូន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធបម្រោះទឹកកខ្វក់ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធបម្រោះទឹកកខ្វក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការប្រែក្លាយ និងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការដំឡើងនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ទៅជាអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

- យោងប្រកាសលេខ ០៤៦ ប្រក.សក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលសមាសភាពមន្ត្រីអ្នកនាំពាក្យប្រចាំក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងសេចក្តីសម្រេចលេខ ៣៥២ សសរ.សក.អរល ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលសមាសភាពក្រុមអ្នកនាំពាក្យនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ១** .-

ត្រូវបានកែសម្រួលសមាសភាពក្រុមអ្នកនាំពាក្យ នៃក្រសួងសាធារណការ និងដឹកជញ្ជូន បន្ថែមលើមុខងារបច្ចុប្បន្ន ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| - ឯកឧត្តម | **ប៉ាល់ ចន្ទសារា** | រដ្ឋលេខាធិការ | ប្រធាន |
| - ឯកឧត្តម | **គង់ វិមាន** | អនុរដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ | អនុប្រធាន |
| - ឯកឧត្តម | **ឯក រដ្ឋ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| - ឯកឧត្តម | **ទ៉ាស៊ីម សុរិយា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| - ឯកឧត្តម | **ហ៊ាង សុទ្ធាយុត្តិ** | អគ្គនាយកបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ | អនុប្រធានអចិន្ត្រៃយ៍ |
| - ឯកឧត្តម | **កែន រដ្ឋា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| - ឯកឧត្តម | **ហោង រត្នពិសិដ្ឋ** | អគ្គនាយកសាធារណការ | សមាជិក |
| - ឯកឧត្តម | **ឈួន ចន់** | អគ្គនាយកដឹកជញ្ជូនផ្លូវគោក | សមាជិក |
| - ឯកឧត្តម | **ឈៀង ពេជ្រ** | អគ្គនាយកភស្តុភារកម្ម | សមាជិក |
| - ឯកឧត្តម | **សឿន ប៊ុនលី** | អគ្គនាយកផែនការ និងគោលនយោបាយ | សមាជិក |
| - ឯកឧត្តម | **ហ៊ាង ចុន្ថា** | អគ្គនាយកបច្ចេកទេស | សមាជិក |
| - ឯកឧត្តម | **ម៉ក់ ស៊ីដេត** | អគ្គនាយកដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ | សមាជិក |
| - ឯកឧត្តម | **ស្ទួន តារិទ្ធ** | អគ្គនាយកប្រព័ន្ធបង្ហូរទឹកកខ្វក់ | សមាជិក |
| - ឯកឧត្តម | **ហឿន សំឡៀង** | នាយកវិទ្យាស្ថាន តេជោសែន សាធារណការ និងដឹកជញ្ជូន | សមាជិក |
| - លោក | **លឹម សុខតៃ** | អគ្គនាយកមន្ទីរសោធន៍សំណង់ និងសាធារណការ | សមាជិក |

**ប្រការ២** .-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣** .-

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូន អគ្គាធិការនៃអគ្គាធិការដ្ឋាន មន្ទីរពិសោធន៍សំណង់ និងសាធារណការ គ្រប់នាយកដ្ឋាន ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត ប្រធានអង្គភាពក្រោមឱវាទក្រសួង និងសាមីខ្លួនដូចមានក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ...ពុធ...៥...រោច...ខែ...បុស្ស...ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី...១១......ខែ..មករា..ឆ្នាំ២០២៣

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

ស៊ុន_ចាន់ថុល

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរាជកិច្ច នៃទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត

  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ ៣

  *"ដើម្បីអនុវត្ត"*
- ឯកសារ កាលប្បវត្ត